ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ៣/៤ [illegible]

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០១៨

## ជម្រាបជូន

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយអាហារូបករណ៍ប្រទេសណូវែលហ្សេឡង់ សម្រាប់ប្រទេសកម្ពុជាក្រោមកម្មវិធីអាហារូបករណ៍ **"អាស៊ាន-ណូវែលហ្សេឡង់ New Zealand ASEAN Scholarship (NZAS) ២០១៨"** សម្រាប់ថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ តាមគ្រឹះស្ថាននានានៅប្រទេសណូវែលហ្សេឡង់សម្រាប់ឆ្នាំសិក្សា២០១៨ ។

**យោង** : លិខិតចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ IDP Education (Cambodia)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា កម្មវិធីជំនួយរបស់ប្រទេសណូវែលហ្សេឡង់ (New Zealand Aid Programme) បានផ្តល់អាហារូបករណ៍ថ្នាក់បណ្ឌិត ថ្នាក់អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ សម្រាប់ឆ្នាំសិក្សា២០១៨ តាមគ្រឹះស្ថាននានានៅប្រទេសណូវែលហ្សេឡង់ក្រោមកម្មវិធីអាហារូបករណ៍ **"អាស៊ាន-ណូវែលហ្សេឡង់ New Zealand ASEAN Scholarship (NZAS) សម្រាប់ឆ្នាំ២០១៨"**។ អាហារូបករណ៍នេះមានគោលបំណងបង្កើនចំណេះដឹង និងជំនាញដើម្បីរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ចំពោះមន្ត្រីរាជការ ដែលមានបំណងចង់ចូលរួមប្រឡងប្រជែងយកអាហារូបករណ៍ខាងលើ សូមស្វែងរកព័ត៌មានលម្អិត និងលក្ខខណ្ឌជ្រើសរើសផ្សេងៗ តាមរយៈគេហទំព័រ www.mfat.govt.nz/scholarships ឬអាចទំនាក់ទំនងព័ត៌មានដោយផ្ទាល់ទៅការិយាល័យកម្មវិធីជំនួយរបស់ប្រទេសណូវែលហ្សេឡង់ (NZAS) នៅ IDP Education (Cambodia) ដែលមានទីតាំងនៅក្នុងមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការបណ្តុះបណ្តាល (ACE) សាខាទួលទំពូង **ផ្ទះលេខ១៦៧ ផ្លូវ១៦៣ កែងផ្លូវ៤៨០ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: ០២៣ ២២២ ០៦៣**។ អាហារូបករណ៍នេះ នឹងផុតកំណត់ឈប់ទទួលពាក្យនៅវេលាម៉ោង១២:០០រសៀល (ម៉ោងនៅណូវែលហ្សេឡង់) **ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨**។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម និងលោកជំទាវ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំអឿន

**សូមទំនាក់ទំនង:**

- លោក ងួន គឹមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧